# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

BUILDING CAPACITY
FOR CHANGE

## លក្ខន្តិកៈ

## អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(អេ ភី អាយ)

**Advocacy and Policy Institute Organization (API)**

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

លក្ខន្តិកៈ
ស.អ

# ជំពូកទី១

## អំពីទស្សនវិស័យ បេសកកម្ម គុណតម្លៃនិងជំនឿ គោលដៅ វិស័យការងារនិងក្រុមគោលដៅ

ប្រការ១៖ **ក/ អំពីទស្សនវិស័យ**

អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយហៅកាត់ថា អង្គការAPI មានទស្សនវិស័យថាប្រទេសកម្ពុជាមានសុខដុមរមនា និរន្តរភាពលទ្ធិប្រជាធិបតេយ្យ ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចតាមរយៈការកាត់បន្ថយភាពក្រីក្រ និងការពារសិទ្ធិមនុស្ស។

**ខ/ អំពីបេសកកម្ម**

បេសកកម្មរបស់អង្គការAPI គឺដើម្បីបម្រើនូវតម្រូវការចាំបាច់ផ្នែកការអភិវឌ្ឍន៍សង្គម និងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យរយៈពេលយូរអង្វែង តាមរយៈការពង្រឹងសិទ្ធិអំណាចប្រជាជនក្នុងការទំនាក់ទំនងជាមួយរដ្ឋាភិបាល ដើម្បីការពារសិទ្ធិ និងឆ្លើយតបនឹងតម្រូវការរបស់ពួកគេ។

អង្គការAPI សន្យានឹងបន្តបេសកកម្មរបស់ខ្លួន ដោយអនុលោមទៅតាមគោលនយោបាយសហប្រតិបត្តិការអន្តរជាតិ និងនីតិរដ្ឋគោរពច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជា ហើយនិងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានប្រសើរបំផុត។ អង្គការAPI តាំងចិត្តធ្វើការជាមួយស្ថាប័នជាតិ និងអន្តរជាតិដែលបានចូលរួមចែករំលែកទស្សនៈរបស់ខ្លួនជួយគាំទ្រក្នុងការផ្លាស់ប្តូរសង្គមឲ្យបានប្រសើរ និងមានសន្តិភាពព្រមទាំងបង្កើនសមត្ថភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទាំងអស់។ អង្គការAPI បានខិតខំស្វះស្វែងស្ថាបនាចំណងទាក់ទងល្អ ដើម្បីផ្សារភ្ជាប់រវាងរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ និងស្ថាប័នឯកជននានា។

**គ/ អំពីគុណតម្លៃ និងជំនឿ**

- ប្រជាពលរដ្ឋខ្មែរទាំងអស់មានសិទ្ធិចូលរួមប្រមែប្រមូល និងសម្តែងចេញនូវរាល់បញ្ហាទាំងឡាយណាដែលបានប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។
- រាល់បញ្ហាទាំងអស់គួរតែដោះស្រាយដោយសន្តិវិធី និងធ្វើឲ្យបានត្រឹមត្រូវទៅតាមគោលការណ៍ទាំងឡាយក្នុងនាមជាមនុស្សជាតិដូចគ្នា។

- ការកសាងសមត្ថភាពជាពិសេសនៅថ្នាក់មូលដ្ឋាន គឺជាវិធីសាស្ត្រមួយសំខាន់ដែលធ្វើឲ្យមាននិរន្តរភាពបំផុតសម្រាប់ការកសាងអនាគតដ៏ភ្លឺស្វាងរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់។
- ការផ្សារភ្ជាប់ជាមួយគ្រប់ផ្នែកក្នុងសង្គមទាំងអស់ គឺដើម្បីធានាឲ្យបាននូវដំណោះស្រាយមួយដែលល្អសម្រាប់ជាប្រយោជន៍ដល់សហគមន៍។
- តម្លាភាព ឯករាជភាព និងការមិនប្រកាន់បក្សនយោបាយ នឹងជួយស្ថាបនាអង្គការមួយដែលធ្វើឲ្យមានការគោរព និងជំនឿទុកចិត្តក្នុងចំណោមប្រជាពលរដ្ឋម្ចាស់ជំនួយអន្តរជាតិ និងអ្នកគាំទ្រ។

**ឃ/ អំពីគោលបំណង**

គោលបំណងរបស់អង្គការAPI គឺពង្រឹងសមត្ថភាពអ្នកតស៊ូមតិខ្មែរដែលធ្វើការលើបញ្ហាសមធម៌ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៅក្នុងប្រទេសកម្ពុជា។

**ង/ អំពីវិស័យការងារស្នូល**

ការងារស្នូលរបស់អង្គការAPI រួមមាន:

- ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព
- ការលើកកម្ពស់ចំពោះការអនុវត្តន៍ច្បាប់ និងគោលនយោបាយជាតិ និងអន្តរជាតិនានាដោយផ្សារភ្ជាប់ជាមួយការស្រាវជ្រាវ ការវិភាគ និងការអភិវឌ្ឍន៍គោលនយោបាយក្នុងវិស័យនានាដូចជា សង្គម សេដ្ឋកិច្ច បរិស្ថាន អប់រំ ។
- ការអភិវឌ្ឍន៍ស្រាវជ្រាវតាមរយៈភាពជាដៃគូ
- ការផ្តល់ប្រឹក្សាយោបល់ និងជំនួយផ្នែកបច្ចេកទេស
- ការអភិវឌ្ឍន៍យុទ្ធនាការតស៊ូមតិ
- មានការគាំទ្រលទ្ធិប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន
- លើកកម្ពស់អភិបាលកិច្ចល្អ និងគោលនយោបាយជួយជនក្រីក្រ
- បោះពុម្ពសម្ភារៈ អប់រំ និងផ្សព្វផ្សាយផ្សេងៗ។

**ច/ អំពីក្រុមគោលដៅ**

ក្រុមគោលដៅរបស់អង្គការAPI គឺអ្នកតស៊ូមតិលើគ្រប់ផ្នែកក្នុងសង្គមរួមទាំង អង្គការសហគមន៍ អង្គការសមាគមមិនមែនរដ្ឋាភិបាល ក្រុមងាយរងគ្រោះ យុវជន ស្ត្រី កុមារ ក្រុមប្រឹក្សាភិបាលមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងព្រមទាំងអ្នកគាំទ្រនៅក្នុងសហគមន៍ជាតិ និងអន្តរជាតិដែលបម្រើផលប្រយោជន៍រួមរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា។

**ជ/ អំពីប្រវត្តិនៃការបង្កើតអង្គការ**

អង្គការAPI បានក្លាយជាអង្គការក្នុងស្រុកចាប់ពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧ នេះតទៅដោយបានផ្លាស់ប្តូរឈ្មោះពី កម្មវិធីតស៊ូមតិ និងគោលនយោបាយ "APP" របស់អង្គការអន្តរជាតិមួយឈ្មោះផេកកម្ពុជា។ APP ក៏បានបង្កើតឡើងដំបូងនៅក្នុង ខែកក្កដា ឆ្នាំ២០០៣ ដោយក្រុមការងារជនជាតិខ្មែរចំនួន៩នាក់ ព្រមទាំងអង្គការអន្តរជាតិ និងមានការចូលរួម ជាមួយអង្គការម្ចាស់ជំនួយមួយចំនួនទៀត។ នៅដើមឆ្នាំ២០០២ អង្គការផេក-កម្ពុជា ក្រោមការណែនាំពីគណៈកម្មាធិការប្រឹក្សាយោបល់ការតស៊ូមតិ (AAC) រួមទាំងតំណាងពីអង្គការជាតិ និងអន្តរជាតិចំនួន៩ បានផ្តួចផ្តើមមានការពិនិត្យស្រាវជ្រាវយុទ្ធនាការតស៊ូមតិនៅក្នុងប្រទេសកម្ពុជា គឺចាប់ពីឆ្នាំ១៩៩៧ រហូតដល់២០០១។ ការស្រាវជ្រាវនេះលើកយកភាពចាំបាច់នានា ក្នុងការជួយបង្កើនជំនាញបច្ចេកទេសការតស៊ូមតិនៅក្នុងសង្គមស៊ីវិលកម្ពុជា និងដើម្បីបង្កើនទំនាក់ទំនងជាមួយ រាជរដ្ឋាភិបាលកម្ពុជាឲ្យកាន់តែប្រសើរឡើង។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះកម្មវិធីតស៊ូមតិ និងគោលនយោបាយ (APP) ក៏ត្រូវបានបង្កើតឡើងដើម្បី ផ្តល់ឲ្យប្រជាពលរដ្ឋខ្មែរធ្វើការតស៊ូមតិលើបញ្ហា សមធម៌ ការកាត់បន្ថយភាពក្រីក្រ និងមានការ អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពគួបផ្សំនូវជំនាញ បច្ចេកទេស និងចំណេះដឹង ដើម្បីរៀបចំប្រតិបត្តិ និងត្រួតពិនិត្យយុទ្ធនាការតស៊ូមតិប្រកបដោយប្រសិទ្ធភាព។

APP មានទីស្នាក់ការដំបូងនៅជាមួយទីស្នាក់ការ អង្គការផេកកម្ពុជា។ APP ក៏បានទទួលនូវកិត្តិស័ព្ទ ជាកម្មវិធីកសាងសមត្ថភាពការតស៊ូមតិ ដែលឈានមុខគេនៅក្នុងប្រទេសកម្ពុជា។ APP បានរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលចំពោះការតស៊ូមតិ សម្រាប់សមាជិកនៃ

អង្គការសង្គមស៊ីវិលកម្ពុជា និងបានផលិតជាឯកសារបោះពុម្ពផ្សាយទុកជាច្រើនមានទាំងភាសាខ្មែរ និងអង់គ្លេស។

APP ក៏បានសម្របសម្រួលវេទិការសង្គមស៊ីវិលជាច្រើន ដែលទាក់ទងនឹងការផ្តួចផ្តើមគោលនយោបាយ និងការតស៊ូមតិក្នុងប្រទេសកម្ពុជា។

ជាលទ្ធផលកម្មវិធីនេះត្រូវបានគេទទួលស្គាល់ និងបានក្លាយជាស្ថាប័នយុទ្ធសាស្ត្រ និងជំនាញផ្នែកតស៊ូមតិចំពោះអង្គការជាដៃគូព្រមទាំងអង្គការមិនមែនជាដៃគូផ្សេងៗទៀត។ ការខិតខំប្រឹងប្រែងទាំងនេះបានបង្កើតគុណប្រយោជន៍ពិតជាក់ស្តែង តាមរយៈការបង្កើនភាពជោគជ័យ និងនិរន្តរភាពនៃយុទ្ធនាការតស៊ូមតិ ដែលមិនត្រឹមតែជួយដល់ដំណើរការលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះទេ វាក៏បានពង្រីកនូវវិសាលភាពនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាផងដែរ។

## ជំពូកទី២

## អំពីឈ្មោះ អាសយដ្ឋាន អត្តសញ្ញាណ សញ្ញាសម្គាល់ និងត្រា

### ប្រការ២៖ **អំពីឈ្មោះ**

អង្គការនេះមានឈ្មោះជាភាសាខ្មែរថា អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ដែលសរសេរជាអក្សរកាត់តាមអក្សរអង់គ្លេសថា (អង្គការ អេ ភី អាយ) និងមានឈ្មោះជាអក្សរអង់គ្លេសថា Advocacy and Policy Institute Organization សរសេរអក្សរកាត់ថា (API)។

### ប្រការ៣៖ **អាសយដ្ឋាន**

អង្គការAPI មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។ ហើយអង្គការអាចមានទីស្នាក់ការសាខាផ្សេងទៀតនៅតាមបណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើតាមតម្រូវការចាំបាច់របស់អង្គការ។ ចំពោះទីស្នាក់ការកណ្តាលអាចមានការផ្លាស់ប្តូរបានក្នុងករណីចាំបាច់តាមការចាំបាច់របស់អង្គការ។

ប្រការ៤៖ **អំពីអត្តសញ្ញាណ**

អង្គការAPI គឺជាអង្គការមួយអព្យាក្រឹតមិនស្វែងរកប្រាក់កម្រៃ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈហិរញ្ញវត្ថុ ឬធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ គឺជា អង្គការបម្រើឲ្យផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ។

ប្រការ៥៖ **អំពីសញ្ញាសម្គាល់ និងត្រា**

ក/ សញ្ញាសម្គាល់របស់អង្គការAPI គឺមានភ្ជាប់នូវឧបសម្ព័ន្ធមួយដោយឡែក។

ខ/ ត្រារបស់អង្គការAPI គឺមានសណ្ឋានជារង្វង់មូលពីរជាន់ដែលជាន់ទី១ខាងលើមានឈ្មោះអង្គការដែលជាភាសាខ្មែរ ហើយផ្នែកខាងក្រោមមានឈ្មោះអង្គការជាភាសាអង់គ្លេស ចំពោះចំនុចកណ្តាលរង្វង់មានសញ្ញាសម្គាល់នៅខាងក្នុងមានទំហំ ៣៤មម និងប្រើទឹកត្រាពណ៌ខៀវ។

## *ជំពូកទី៣*

## *សមាជិកភាព ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព*

ប្រការ៦៖ **សមាជិកភាព**

ប្រជាពលរដ្ឋទាំងពីរភេទគ្រប់អាយុចាប់ពី១៨ឆ្នាំឡើងទៅ គឺមានសិទ្ធិសុំចូលធ្វើជាបុគ្គលិករបស់អង្គការAPI ហើយបុគ្គលិកអង្គការAPI ទាំងអស់ត្រូវគោរពប្រតិបត្តិតាមច្បាប់នានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងគោរពប្រតិបត្តិតាមលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់អង្គការ។

ប្រការ៧៖ **បុគ្គលិករបស់អង្គការAPI មាន៖**

១-បុគ្គលិកស្ថាបនិក គឺជាអ្នកដែលបានផ្តួចផ្តើមដោយអង្គការនេះឡើង។

២-បុគ្គលិកកិច្ចសន្យា គឺជាអ្នកចូលរួមដឹកនាំ និងអនុវត្តសកម្មភាពអង្គការ។

ប្រការ៨៖ **ចំពោះអង្គការAPI អាចជ្រើសរើសបុគ្គលិកឲ្យចូលបម្រើការងារតាមការចាំបាច់របស់អង្គការតាមរយៈ ការធ្វើតេស្តប្រឡងគន្លិកៈនិងចុះកិច្ចសន្យាការងារដោយអនុលោមតាមច្បាប់ការងារក្នុងប្រទេសកម្ពុជា។**

ប្រការ៩៖ **គ្រប់បុគ្គលិករបស់អង្គការត្រូវគោរព និងអនុវត្តតាមលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង បទបញ្ញានានារបស់អង្គការ។**

គ្មានបុគ្គលិកណាម្នាក់យកឈ្មោះរបស់អង្គការ ទៅបម្រើផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួន ឬផលប្រយោជន៍ឲ្យគណបក្សនយោបាយណាមួយឡើយ។

ប្រការ១០៖ **ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព**

លក្ខខណ្ឌនៃការបាត់បង់សមាជិកភាព និងបុគ្គលិកភាពអង្គការមានដូចខាងក្រោម៖

- ទទួលមរណភាព
- ចប់កិច្ចសន្យាការងារ
- បានដាក់ពាក្យលាឈប់ដោយផ្ទាល់ជាលាយលក្ខណ៍អក្សរជូនគណៈកម្មការប្រតិបត្តិឲ្យបានមុននឹងលាឈប់ពីការងារ តាមគោលការណ៍របស់អង្គការ។
- មិនគោរពតាមលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងរបស់អង្គការ និងសេចក្តីសម្រេចផ្សេងៗរបស់អង្គការ ហើយត្រូវបានបណ្តេញចេញដោយសេចក្តីសម្រេចរបស់គណៈកម្មការប្រតិបត្តិតាមសំឡេង២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិបន្ទាប់ពីបានទទួលការណែនាំពីប្រធានអង្គការចំនួន២ដងរួចហើយ ប៉ុន្តែនៅតែពុំព្រមកែខ្លួនទៀត។
- មានជាប់ពិរុទ្ធបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌណាមួយដែលចេញសាលក្រម ឬសាលដីកាស្ថាពរដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា។
- មានជំងឺវិកលចរិតដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យដែលស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ១១៖ **ក្នុងករណីមានការបញ្ឈប់សមាជិក ឬបុគ្គលិកណាមួយគណៈកម្មការប្រតិបត្តិត្រូវប្រជុំគ្នាដើម្បីជ្រើសរើសអ្នកថ្មីដើម្បីមកជំនួស។**

## *ជំពូកទី៤*

## *អំពីរចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច*

ប្រការ១២៖ **អង្គការAPI មានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖**

**ក-ក្រុមប្រឹក្សាភិបាល** គឺជាស្ថាប័នកំពូលរបស់អង្គការAPI ដែលក្រុមប្រឹក្សាភិបាលរួមមានប្រធាន១រូប និងសមាជិក ៤រូប ឬ ៦រូប ឬច្រើននាក់ទៀត ។ ហើយចំពោះសមាជិក

ក្រុមប្រឹក្សាភិបាលអាចមានអាណត្តិរយៈពេលត្រឹម៥ឆ្នាំ និងអាចកាន់តំណែងនេះបានយ៉ាងយូរ ២អាណត្តិ។ ហើយសមាជិកក្រុមប្រឹក្សាភិបាលនឹងអាចបន្តអាណត្តិថ្មីបន្ថែមបានមួយអាណត្តិទៀតរយៈពេល(៥ឆ្នាំ) នៅក្នុងករណីមានការឯកភាព២ភាគ៣នៃក្រុមប្រឹក្សាភិបាលសរុបទាំងអស់។ ប៉ុន្តែបើប្រសិនជាអាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវបានបញ្ចប់ព្រមគ្នាក្នុងពេលតែមួយនោះគឺតម្រូវឲ្យមានសមាជិកម្នាក់ ឬច្រើននាក់(យ៉ាងច្រើនចំនួនពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាភិបាល)អាចមានសិទ្ធិបន្តអាណត្តិបានរយៈពេលមួយឆ្នាំទៀត។ អង្គការAPI ព្យាយាមធ្វើយ៉ាងណាឲ្យមានសមភាពយេនឌ័រនៅក្នុងចំណោមតំណែងក្រុមប្រឹក្សាភិបាល ហើយភាគច្រើននៃក្រុមប្រឹក្សាភិបាលត្រូវតែមានសញ្ជាតិខ្មែរ។

សមាជិកក្រុមប្រឹក្សាភិបាលថ្មីត្រូវបានជ្រើសរើសទីតាំង និងបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាភិបាលក្នុងតំណែង។ ប្រសិនបើសមាជិកណាមួយមិនបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងគោលការណ៍ក្រុមប្រឹក្សាភិបាលទេនោះ នឹងត្រូវបានបញ្ឈប់ពីតំណែងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ដោយមានសន្លឹកឆ្នោត (៥០ភាគរយបូកមួយ) នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែមានចំនួនសេស(ប្រាំ ប្រាំពីរ...ល...) ដើម្បីជៀសវាងភាពជាប់គាំង ឬរាំងស្ទះដល់ដំណើរការរបស់អង្គការដែលអាចបណ្តាលមកពីការសម្រេចចិត្តនានាក្នុងករណីសម្លេងឆ្នោតស្មើគ្នា។

**ខ-គណៈកម្មការប្រតិបត្តិ** ដឹកនាំដោយនាយកប្រតិបត្តិជាប្រធានចំនួន១រូប និងសមាជិកជាប្រធានផ្នែកផ្សេងៗនៃអង្គការAPI។

ប្រការ១៣៖ **សន្និបាត ឬអង្គប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការAPI មានពីរប្រភេទគឺ សន្និបាត ឬអង្គប្រជុំសាមញ្ញ និងសន្និបាតឬអង្គប្រជុំវិសាមញ្ញ។**

ប្រការ១៤៖ **សន្និបាត ឬអង្គប្រជុំសាមញ្ញ គឺប្រារព្ធធ្វើឡើង២ដងជារៀងរាល់ឆ្នាំដើម្បី៖**

- មានការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលដែលចប់អាណត្តិ។
- ធ្វើការជ្រើសរើសនាយកប្រតិបត្តិនៅពេលដែលមានការចប់អាណត្តិ។
- ពិនិត្យ និងវាយតម្លៃការងាររបស់នាយកប្រតិបត្តិប្រចាំឆ្នាំ និងអាណត្តិ។
- ពិនិត្យ និងវាយតម្លៃរបាយការណ៍ពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុថវិកាប្រចាំឆមាស និងប្រចាំឆ្នាំ។

- ពិនិត្យ និងអនុម័តលើទិសដៅគោលបំណង និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬច្បាប់ការងារ។
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀតដែលបានស្នើឡើងដោយគណៈកម្មការប្រតិបត្តិ។
- ធានាឲ្យបាននូវស្ថិរភាព និងតម្លាភាពហិរញ្ញវត្ថុរបស់អង្គការAPI។
- មានការចូលរួមក្នុងការរៃអង្គាសមូលនិធិដោយសហការជាមួយនាយកប្រតិបត្តិ។
- ចាត់ចែង អនុម័ត និងទទួលយកការវាយតម្លៃហិរញ្ញវត្ថុប្រចាំឆ្នាំ និងប្រចាំឆមាស ដែលចុះហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ហើយធ្វើការចងក្រងជាឯកសារទុកក្នុងការិយាល័យរបស់អង្គការ។
- ធានាឲ្យបាននូវការវាយតម្លៃផ្សេងៗ និងការជម្រះបញ្ជីហិរញ្ញវត្ថុដែលអង្គការផ្តល់ជំនួយតម្រូវឲ្យធ្វើ និងត្រូវបានរៀបចំដោយប៊ិនប្រសប់ការចំណាយមានប្រសិទ្ធភាព និងដោយត្រឹមត្រូវតាមពេលកំណត់។
- ត្រូវធ្វើជាតំណាងឲ្យអង្គការAPI ជាសារធារណៈ និងជួយលើកស្ទួយអង្គការAPI។

ប្រការ១៥៖ **អង្គប្រជុំវិសាមញ្ញ**

ក្នុងករណីចាំបាច់ឬពិសេសអង្គការAPI អាចរៀបចំអង្គប្រជុំវិសាមញ្ញបានដោយមិនមានកំណត់ពេលវេលាតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល តាមសំណើសុំភាគច្រើនដាច់ខាត(៥០%+១) នៃសមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ ឬតាមសំណើសុំរបស់នាយកប្រត្តិបត្តិ ឬតាមសំណើសុំ២/៣ នៃចំនួនសមាជិកគណៈកម្មការប្រតិបត្តិ។

សន្និបាតវិសាមញ្ញមានភារកិច្ចៈ

- ពិនិត្យពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈក្នុងករណីចាំបាច់។
- ពិនិត្យ និងសម្រេចលើការវាយតម្លៃការងារ និងការផ្លាស់ប្តូរនាយកប្រតិបត្តិ។
- ពិនិត្យ និងអនុម័តលើការរំលាយអង្គការ និងការចាត់ចែងទ្រព្យសម្បត្តិ។
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀតដែលចាំបាច់នៅក្នុងអង្គការ ។

ប្រការ១៦៖ **លក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គប្រជុំទាំងពីរប្រភេទ គឺមានតម្លៃគតិយុត្តបានលុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត(៥០%+១) លើការចូលរួមក្នុងអង្គប្រជុំយ៉ាងហោចណាស់២/៣នៃសមាជិកក្រុមប្រឹក្សាភិបាល។ ក្នុងករណីមានសំឡេងស្មើ

គ្នានៃក្រុមប្រឹក្សាភិបាល សំឡេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។ ប្រធានអង្គប្រជុំជាប្រធានក្រុមប្រឹក្សាភិបាល ឬសមាជិកនៃក្រុមប្រឹក្សាភិបាល ដែលមានឯករាជ្យភាពតាមការជ្រើសរើសរបស់អង្គសន្និបាត។ ហើយសមាជិកក្រុមប្រឹក្សាភិបាលអាចផ្ទេរសិទ្ធិ (proxy vote) បានទៅឲ្យសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ក្នុងការធ្វើសេចក្តីសម្រេចចិត្តជំនួសនៅពេលដែលសាមីខ្លួនមិនអាចចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

ប្រការ១៧៖ **កិច្ចប្រជុំគណៈកម្មការប្រតិបត្តិរបស់អង្គការAPI ចែកចេញជាពីរប្រភេទគឺកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។**

កិច្ចប្រជុំសាមញ្ញរបស់គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំគ្នា១ដងក្នុង១ត្រីមាស ដើម្បីដឹកនាំប្រតិបត្តិការអង្គការ និងក្នុងករណីចាំបាច់ ឬពិសេសអង្គការAPIអាចរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មការប្រតិបត្តិបានដោយមិនបានកំណត់ពេលវេលា តាមការអញ្ជើញរបស់ប្រធានអង្គការដើម្បីពិនិត្យពិភាក្សា និងអនុម័តលើរបៀបវារៈដែលបានដាក់ជូនដោយប្រធានអង្គការ ឬសមាជិកគណៈកម្មការប្រតិបត្តិដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) ក្នុងនោះគោលបំណងដើម្បីរិះរកយុទ្ធវិធីអនុវត្តសកម្មភាពការងាររបស់អង្គការឲ្យមានភាពរីកចម្រើន។

ប្រការ១៨៖ **សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការប្រតិបត្តិទាំងពីរប្រភេទមានលក្ខណៈជាគតិយុត្តបានតាមការអនុម័តដោយមានសំឡេងគាំទ្រ(៥០%+១) លើការចូលរួមក្នុង សន្និបាត ឬអង្គប្រជុំយ៉ាងហោចណាស់២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិ។**

ប្រការ១៩៖ **អង្គការAPI បានដឹកនាំ និងគ្រប់គ្រងដោយមានគណៈកម្មការប្រតិបត្តិ។**

ប្រធានគណៈកម្មការប្រតិបត្តិ គឺជាប្រធានអង្គការដែលមានអាណត្តិរយៈពេល៥ឆ្នាំ ហើយមានចំនួន២អាណត្តិជាប់គ្នា(១០ឆ្នាំ) ដែលបានជ្រើសរើសតាមរយៈក្រុមប្រឹក្សាភិបាលរបស់អង្គការ និងអាចបន្តអាណត្តិថ្មីបន្ថែមបានមួយអាណត្តិទៀត(៥ឆ្នាំ) ក្នុងករណីមានការឯកភាព២/៣ នៃក្រុមប្រឹក្សាភិបាលសរុបទាំងអស់។ គាត់មានសិទ្ធិទទួលបានការងារផ្សេងក្នុងអង្គការAPI ឧទាហរណ៍ជាទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ក្រោយពេលចប់ជាប្រធានអង្គការ។

នៅចុងបញ្ចប់នៃអាណត្តិនីមួយៗរយៈពេល៥ឆ្នាំ ក្រុមប្រឹក្សាភិបាលនឹងធ្វើការពិនិត្យឡើងវិញនូវការអនុវត្តន៍ ដោយផ្អែកនូវផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ។

ការពិនិត្យឡើងវិញនេះនឹងរួមបញ្ចូលនូវមតិយោបល់ពីម្ចាស់ជំនួយភាគីពាក់ព័ន្ធ និង បុគ្គលិក។ នៅចុងបញ្ចប់នៃដំណើរការត្រួតពិនិត្យនេះ ក្រុមប្រឹក្សាភិបាលមានជម្រើសថា កិច្ចសន្យារយៈពេល៥ឆ្នាំថ្មីនឹងត្រូវបានផ្តល់ជូននាយកប្រតិបត្តិបច្ចុប្បន្នឬ ជ្រើសរើស នាយកប្រតិបត្តិថ្មី។

ប្រការ២០៖ **សមាជិកគណៈកម្មការប្រតិបត្តិមានចំនួនយ៉ាងតិច ៣រូបតំណាងផ្នែកនីមួយៗដូច ខាងក្រោម៖**

| | |
|---|---|
| -នាយកប្រតិបត្តិ | ០១រូប |
| -ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ | ០១រូប |
| -ប្រធានកម្មវិធី | ០១រូប ទៅ០៣រូប |

ប្រការ២១៖ **ប្រធានគណៈកម្មការប្រតិបត្តិអង្គការAPI គឺជាប្រធានអង្គការមានតួនាទី និង ភារកិច្ច៖**

- ធ្វើជាតំណាងស្របច្បាប់របស់អង្គការធ្វើការទំនាក់ទំនងជាមួយសហគមន៍ រដ្ឋាភិបាល ដៃគូអភិវឌ្ឍនិង អង្គការជាតិ អន្តរជាតិទាំងក្នុង និងក្រៅប្រទេស ក្នុងកិច្ចសហការនានាដើម្បីសម្រេចតាមទស្សនវិស័យនិងបេសកកម្មអង្គការ
- ធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងការដឹកនាំទាំងមូលរបស់អង្គការ និងជានារាល់ការប្រតិបត្តិសកម្មភាពរបស់គម្រោងស្របតាមទស្សនវិស័យ បេសកកម្មអង្គការ គុណតម្លៃ និងគោលនយោបាយរបស់អង្គការAPI ក្រោម ការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល។
- មានសិទ្ធិសម្រេច និងជ្រើសរើសបុគ្គលិក កាត់បន្ថយបុគ្គលិកឬធ្វើការផ្លាស់ ប្តូរប្រធានផ្នែកផ្សេងៗតាមសេចក្តីត្រូវការចាំបាច់ក្នុងអង្គការ។
- ធ្វើជាគណៈអធិបតីនៅក្នុងអង្គប្រជុំផ្សេងៗ និងមានសិទ្ធិចាត់តាំងបុគ្គលិក ណាម្នាក់ជាតំណាងនៅពេលអវត្តមាន។
- មានការត្រួតពិនិត្យរាល់សកម្មភាពការងារទាំងមូលនៅក្នុងអង្គការ។
- មានសិទ្ធិអនុម័តលើគម្រោងចំណាយ និងចំណូលផ្សេងៗរបស់អង្គការ។
- គ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គការAPI ដោយធ្វើទៅតាមគោលការណ៍ថវិកា និងហិរញ្ញវត្ថុដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ព្រមទាំងមានកាតព្វកិច្ច ទទួលខុសត្រូវរាល់ចំណូល និងចំណាយទាំងអស់។

- មានការទទួលខុសត្រូវលើការគ្រប់គ្រងបុគ្គលិកទាំងអស់ដូចមានចែងនៅក្នុងគោលការណ៍បុគ្គលិករបស់អង្គការAPI ។
- ទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះ (ម្ចាស់មូលនិធិ ក្រុមប្រឹក្សាភិបាល បុគ្គលិក អ្នកទទួលផល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត)។
- ផ្តល់ព័ត៌មានទាន់ពេលដល់ក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យលើលទ្ធផលរបស់អង្គការAPI។
- ត្រូវទទួលខុសត្រូវលើការងារប្រតិបត្តិប្រចាំថ្ងៃទាំងមូលរបស់អង្គការAPI។
- ធ្វើការពិនិត្យកែសម្រួល និងសម្រេចគ្រប់កិច្ចការទាំងអស់។

ប្រការ២២៖ **ក/ រដ្ឋបាលមានតួនាទី និងភារកិច្ច៖**

- ត្រូវតែធ្វើសេចក្តីរាយការណ៍ជូនប្រធានអង្គការ។
- អនុវត្តការងារ និងធ្វើការទទួលខុសត្រូវខ្ពស់នៅក្នុងផ្នែករបស់ខ្លួន។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- ធ្វើការទទួលខុសត្រូវខ្ពស់លើការងារ ផ្នែករដ្ឋបាល ដូចជាទទួលបន្ទុកការងារប្រជុំនានា កត់ត្រាខ្លឹមសារទាំងអស់ និងធ្វើការចងក្រងជារបាយការណ៍ធ្វើសារពើភណ្ឌ និងគ្រប់គ្រងសម្ភារៈដែលជាមធ្យោបាយធ្វើដំណើរសន្តិសុខសណ្តាប់ធ្នាប់ គ្រប់គ្រងលិខិតចេញចូល និងឯកសារផ្សេងៗ។
- ត្រូវអនុវត្តគ្រប់ការងារពាក់ព័ន្ធទៅតាមការស្នើសុំរបស់ប្រធាន។

**ខ/ ហេរញ្ញិក មានតួនាទី និងភារកិច្ច៖**

- ធ្វើការទទួលខុសត្រូវខ្ពស់លើការងារដែលទាក់ទងទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធ្វើសរសេរគម្រោងដើម្បីស្នើសុំថវិកាសម្រាប់ទ្រទ្រង់សកម្មភាពរបស់អង្គការ។
- ធ្វើការរៀបចំ និងចុះបញ្ជីចំណូល-ចំណាយរបស់អង្គការ។
- មានការត្រួតពិនិត្យបញ្ជីចំណូល-ចំណាយរបស់អង្គការ។
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ត្រូវអនុវត្តគ្រប់ការងារពាក់ព័ន្ធទៅតាមការស្នើសុំរបស់ប្រធាន។

ប្រការ២៣៖ **ប្រធានកម្មវិធីមានតួនាទី និងភារកិច្ច**

- ត្រូវរៀបចំកម្មវិធីនានាជូនប្រធានអង្គការពិនិត្យ និងសម្រេច។

- ធ្វើជាជំនួយការឲ្យប្រធានក្នុងការរៀបចំ និងអនុវត្តសកម្មភាពកម្មវិធីផ្សេងៗរបស់អង្គការ។
- ត្រូវតែមានការចូលរួមសម្របសម្រួលការប្រជុំ និងមានការរៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គការ ។
- ត្រូវតែមានការធានារាល់ការប្រតិបត្តិសកម្មភាពរបស់គម្រោងស្របតាមទស្សនវិស័យ បេសកកម្មអង្គការ គុណតម្លៃ និងគោលនយោបាយអង្គការ។
- ត្រូវមានការធានាចំពោះការងារប្រតិបត្តិការប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីបុគ្គលិកក្រុមគោលដៅ និងអ្នកពាក់ព័ន្ធទាំងអស់។
- ការចូលរួមដឹកនាំធ្វើការកំណត់ ហើយបែងចែកការងារចំពោះការទទួលខុសត្រូវដល់បុគ្គលិក និងពិភាក្សាពីតម្រូវការបុគ្គលិក។
- ការចូលរួមដឹកនាំរៀបចំផែនការ និងរបាយការណ៍សកម្មភាព ហើយថវិកាប្រចាំត្រីមាស និងប្រចាំឆ្នាំដាក់ជូនប្រធានគណៈកម្មការប្រតិបត្តិនិងក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ និងអនុម័ត។
- រាល់ការរៀបចំ ឬកែសម្រួលគោលនយោបាយសំខាន់ៗរបស់អង្គការ ដូចជាគោលនយោបាយបុគ្គលិក ហិរញ្ញវត្ថុ លទ្ធកម្ម និងលក្ខន្តិកៈជូនគណៈកម្មការប្រតិបត្តិ និងក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត។
- ធ្វើការពិភាក្សាលើបញ្ហាសំខាន់ៗតាមការស្នើសុំរបស់នាយកប្រតិបត្តិ។
- ការចូលរួមអនុវត្តការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល និងប្រធានគណៈកម្មការប្រតិបត្តិ ឬបំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការប្រតិបត្តិ និងក្រុមប្រឹក្សាភិបាលបានប្រគល់ជូន។

## ជំពូកទី៩

## វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ វិសោធនកម្មលក្ខន្តិកៈ

ប្រការ២៤៖ **អំពីវិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់**

អង្គការAPI អាចប្តូរឈ្មោះបាន ឬប្តូរសញ្ញាសម្គាល់បានតាមសំណើសុំរបស់ប្រធានអង្គការ ដោយមានសំឡេងគាំទ្រភាគច្រើនដាច់ខាត(៥០%+១)នៃសមាជិកគណៈកម្មការប្រតិបត្តិ និងមានការគាំទ្រ២/៣(ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ។

ការអនុម័តលើរាល់ការសម្រេចនៃការប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់របស់អង្គការAPI គឺជាសមត្ថកិច្ចក្រុមប្រឹក្សាភិបាលរបស់អង្គការAPI ។

ប្រការ២៥៖ **អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈ**

លក្ខន្តិកៈរបស់អង្គការAPI អាចធ្វើវិសោធនកម្មបានតាមសំណើសុំរបស់ប្រធានអង្គការតាមសំណូមពរដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត(៥០%+១) នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់អង្គការ និងការគាំទ្រ២/៣(ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ។ ការអនុម័តលើរាល់ការសម្រេច នៃការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់អង្គការគឺជាសមត្ថកិច្ចរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាល។

## ជំពូកទី៦

## អំពីប្រភពមូលនិធិ និងការគ្រប់គ្រង

ប្រការ២៦៖ **អង្គការAPI មានប្រភពមូលនិធិបានមកពី៖**

- ជាធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់អង្គការ
- ប្រភពបានដោយអំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ជាចំណូលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត

ប្រការ២៧៖ **រាល់ចំណូលទាំងអស់របស់អង្គការAPI ត្រូវបានគ្រប់គ្រងដោយហេរញ្ញិករបស់អង្គការ ដោយមានការចុះហត្ថលេខាយល់ព្រមពីប្រធានអង្គការ។**

ចំណូលជាសាច់ប្រាក់ ឬមូលប្បទានប័ត្រទាំងអស់ត្រូវបញ្ចូលទៅក្នុងគណនីធនាគារស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាការសម្រេចរបស់គណៈកម្មការប្រតិបត្តិ។ ថវិកាអាចរក្សាទុកមួយចំនួននៅក្នុងបេឡារបស់អង្គការសម្រាប់ការប្រើប្រាស់ចាំបាច់ក្នុងអង្គការ តាមការកំណត់របស់គណៈកម្មការប្រតិបត្តិ។ រាល់ការដកសាច់ប្រាក់ ឬមូលប្បទានប័ត្រពីធនាគារត្រូវមានចុះហត្ថលេខារបស់ហេរញ្ញិក និងប្រធានអង្គការ ឬអាចផ្ទេរសិទ្ធិទៅឲ្យរូបវន្តបុគ្គលដែលជាសមាជិកគណៈកម្មការប្រតិបត្តិ ឬក្រុមប្រឹក្សាភិបាលតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីសាមីខ្លួនដែលមានសិទ្ធិ។

លក្ខន្តិកៈ
ស.អ

# ជំពូកទី៧

# ការផ្អាកសកម្មភាព ការរំលាយអង្គការ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ

ប្រការ២៨៖ **អំពីការផ្អាកសកម្មភាពអង្គការ**

មានតែសន្និបាតរបស់ក្រុមប្រឹក្សាភិបាល និងការគាំទ្រសំឡេង២/៣នៃសមាជិកគណកម្មការប្រតិបត្តិតែមួយគត់ដែលអាចសម្រេចក្នុងការផ្អាកសកម្មភាពរបស់អង្គការAPI នេះបាន។ មុនពេលអង្គការត្រូវបានផ្អាកសកម្មភាព សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយ ដើម្បីគ្រប់គ្រងនូវទ្រព្យសម្បត្តិរបស់អង្គការ។

ប្រការ២៩៖ **អំពីការរំលាយអង្គការ**

មានតែសន្និបាតក្រុមប្រឹក្សាភិបាល និងការគាំទ្រសំឡេង២/៣នៃសមាជិកគណកម្មការប្រតិបត្តិតែមួយគត់ ដែលអាចសម្រេចក្នុងការរំលាយអង្គការAPIនេះបាន។ មុនពេលអង្គការត្រូវបានរំលាយសន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជីអង្គការ។

ប្រការ៣០៖ **អំពីចាត់ចែងទ្រព្យសម្បត្តិ**

រាល់ទ្រព្យសម្បត្តិរបស់អង្គការAPI ដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់អង្គការរួចត្រូវប្រគល់ជូនសមាគមជាតិកាកបាទក្រហមកម្ពុជា ឬសមាគមអង្គការដែលមានគោលបំណងប្រហាក់ប្រហែល និងអង្គការAPI។ សមាជិក និងបុគ្គលិកអង្គការទាំងអស់ក៏ត្រូវរំសាយផងដែរនៅពេលដែលអង្គការត្រូវបានរំលាយ ។

# ជំពូកទី៨

# អវសានប្បញ្ញត្តិ

ប្រការ៣១៖ **រាល់បទប្បញ្ញត្តិទាំងឡាយណារបស់អង្គការAPI ដែលមានខ្លឹមសារផ្ទុយពីលក្ខន្តិកៈនេះត្រូវបានទុកជានិរាករណ៍។**

ប្រការ៣២៖ អង្គការAPI ត្រូវធ្វើសកម្មភាពដោយអនុវត្តឲ្យស្របតាមលក្ខន្តិកៈរបស់ខ្លួនដូចដែលបានតម្កល់ទុកក្នុងក្រសួងមហាផ្ទៃច្បាប់ស្ដីពីសមាគម និងអង្គការមិនមែន រដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ប្រការ៣៣៖ លក្ខន្តិកៈរបស់អង្គការAPI មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ៕

បានពិនិត្យ និងសម្រេចកែលម្អលើលក្ខន្តិកៈ
បានចុះបញ្ជី និងតម្កល់នៅក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧
ដើម្បីឲ្យស្របនឹងច្បាប់ស្ដីពីសមាគមអង្គការមិនមែនរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
ថ្ងៃ...........................ខែ............ឆ្នាំរកា នព្វស័ក ព.ស២៥......

រាជធានីភ្នំពេញ,ថ្ងៃទី 15 ខែ មិថុនា ឆ្នាំ២០...18

**គណៈកម្មការប្រតិបត្តិ**
នាយកប្រតិបត្តិ

ឡាំ សុជាតិ

**ក្រុមប្រឹក្សាភិបាល**
ប្រធាន

សៀង ច័ន្ទតារា

**បានតម្កល់ទុកលក្ខន្តិកៈ**
របស់
[illegible]
ដែលបានធ្វើវិសោធនកម្ម នៅក្រសួងមហាផ្ទៃ តាមលិខិត
លេខ:១២៨៨ សជណ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៨។
រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៨
**នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ**
ប្រធាន

លក្ខន្តិកៈ
ស.អ

**ឈឹម គាន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រចនាសម្ព័ន្ធ**

**អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(អេ ភី អាយ)**

Advocacy and Policy Institute Organization

**ក្រុមប្រឹក្សាភិបាល**
ប្រធាន: សៀង ច័ន្ទតារា
សមាជិក: កាសូមី ណាហ្គាកាវ៉ា, គីម សុខលាង,
ប៉ក់ គឹមជឿន, ឃួន ប៊ុនសាំង, ម៉ៃឃើល អេងឃ្វីស...

**គណៈកម្មការប្រតិបត្តិ**
ប្រធាន: លោក ឡាំ សុជាតិ

**ទីប្រឹក្សា**

**ប្រធានកម្មវិធី**
*លោកស្រី មាស លីដា*
*លោក ផាន ភ័ក្ដបារមី*
*លោក ម៉ាន់ វ៉ាន់ផាន់និត*

**រដ្ឋបាល**
**ហេរញ្ញិក**
*លោកស្រី ជន សុម៉ាលី*

ថ្ងៃ............................ខែ.............ឆ្នាំរកា នព្វស័ក ព.ស២៥......

រាជធានីភ្នំពេញ,ថ្ងៃទី 15 ខែ [illegible] ឆ្នាំ២០.....៨

**គណៈកម្មការប្រតិបត្តិ**
នាយកប្រតិបត្តិ

ឡាំ សុជាតិ

**ក្រុមប្រឹក្សាភិបាល**
ប្រធាន

សៀង ច័ន្ទតារា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបសម្ព័ន្ធ**

**របស់**

**អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(អេ ភី អាយ)**

Advocacy and Policy Institute Organization API

**ក/សញ្ញាសម្គាល់**

**អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(អេ ភី អាយ)**

API
BUILDING CAPACITY
FOR CHANGE

**ខ/ត្រា**

ថ្ងៃ......................ខែ.............ឆ្នាំរកា នព្វស័ក ព.ស២៥.......

ថ្ងៃទី 15 ខែ មិថុនា ឆ្នាំ២០..18

**គណៈកម្មការប្រតិបត្តិ**
នាយកប្រតិបត្តិ
ឡាំ សុជាតិ

**ក្រុមប្រឹក្សាភិបាល**
ប្រធាន
សៀង ច័ន្ទតារា